# សម្រង់ឯកសារអំពីរឿង ព្រំដែនខ្មែរ និង កោះត្រល់ ជាមួយវៀតណាម

(ដោយលោក ម៉ែន ណាត «Mèn Nath» ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា /ឆ្នាំ២០១៩)

## ជុំវិញរឿងព្រំដែនគោក

- ព្រះរាជសារ សម្តេចតា នរោត្តម ស៊ីហនុ ចុះក្នុង BMD ថ្ងៃទី១៨ ធ្នូ ២០០៤ (ឯកសារភាសាអង់គ្លេស និង បារាំង) ថា លោក វ៉ា គឹមហុង ប្រើ «ផែនទីក្លែងក្លាយ» ដោះស្រាយបញ្ហាព្រំដែនជាមួយ វៀតណាម។ លោក វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការព្រំដែន នៃរដ្ឋាភិបាលលោក ហ៊ុន សែន។
- លោក វ៉ា គឹមហុង កាលពីថ្ងៃទី០២ កក្កដា ២០១៥ ទទួលស្គាល់ថា **«ផែនទី បោះបង្គោលព្រំដែន ជាមួយវៀតណាម គឺជាផែនទី យូធីអឹម** (UTM របស់ទាហានអាមេរិកាំង ក្នុងសម័យសង្គ្រាមវៀតណាម) **ខ្នាត ១/៥០.០០០ មាន ៤០ ផ្ទាំង និង ផែនទីបោន** (Bonne) **១/១០០.០០០ មាន ២៦ ផ្ទាំង ហើយជាផែនទី បោះពុម្ពនៅប្រទេសវៀតណាម»** ជាផែនទី **អមភ្ជាប់**នឹងសន្ធិញ្ញាព្រំដែនរដ្ឋ ថ្ងៃទី ២៧ ធ្នូ ១៩៨៥។

- សម្តេចតា នរោត្តម សីហនុ នៅថ្ងៃទី១៩ កក្កដា ១៩៩៣ សរសេរលិខិតទៅសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និង លោក ហ៊ុន **សែន ឲ្យប្រាប់ទៅមេដឹកនាំវៀតណាម ថាត្រូវយកបង្គោលព្រំដែន សម័យបារាំង ទាំង ១២៤ បង្គោល ទៅដាក់ត្រង់កន្លែងដើមវិញ**។ ទ្រង់ រណឫទ្ធិ លោក ហ៊ុន សែន កាលនោះ ជាសហនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបណ្តោះអាសន្ន ក្រោយការបោះឆ្នោតជាតិ ខែឧសភា ១៩៩៣។ អ្នកទាំងពីរ មិនបានធ្វើតាមការទាមទាររបស់សម្តេចតាទេ។

- សន្ធិសញ្ញា ១៩៨៣ ស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែន និង កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈព្រំដែន ធ្វើឡើងនៅថ្ងៃទី ២០ កក្កដា ១៩៨៣ រវាងលោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ជាមួយលោក ង្វៀន កីថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម។

- ព្រះរាជសារសម្តេច នរោត្តម សីហនុ ថ្ងៃ១៦ មីនា ២០០៥ ចុះផ្សាយព្រឹត្តប័ត្រ BMD ជាភាសាបារាំង ថា«សាធារណរដ្ឋសង្គមនិយមវៀតណាម បានបង្កើតព្រំដែនថ្មី (ចំណេញទៅគេ) ដោយសាងសង់ នៅទសវត្សរ៍ទី ៨០ និងឆ្នាំ១៩៩០-២០០០ នូវក្លោងទ្វារ ហើយដោយ ***«ជីកប្រឡាយទឹក ដែលស្ថិតនៅក្នុងទឹកដីប្រទេសកម្ពុជា ឆ្ងាយពីព្រំដែនយើង កាលពីឆ្នាំ១៩៦៣-១៩៦៩»***។ «កម្ពុជាយើងសព្វថ្ងៃ តំណាងដោយក្រុមឯកឧត្តម វ៉ា គឹមហុង យល់ព្រម ***«ធ្វើអត្តឃាតខ្លួនឯង»*** **ដោយទទួលស្គាល់ សូម្បីតែនៅចំពោះមុខច្បាប់អន្តរជាតិថា ប្រទេសកម្ពុជា គ្មានព្រំដែនច្បាស់លាស់ទេ»**។

- សន្ធិសញ្ញាព្រំដែន ឆ្នាំ២០០៥ និងសន្ធិសញ្ញាព្រំដែន ឆ្នាំ២០១៩ គឺគ្រាន់តែបន្ថែមខ្លឹមសារទៅលើ សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ គឺថាវាសុទ្ធតែយកមូលដ្ឋានគ្រឹះនៃ សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ (ខុសច្បាប់) ថ្ងៃ ២៧ ធ្នូ ១៩៨៥ (ចុះហត្ថលេខាដោយលោក ហ៊ុន សែន និង ង្វៀន កូថាច់) ដែលជាសន្ធិសញ្ញា ធ្វើឡើងក្រោមការត្រួតត្រា របស់វៀតណាម ដែលបង្កឲ្យមានទំនាស់ផ្លូវច្បាប់ ត្រូវបានប្រឆាំងជំទាស់ដោយក្រុមអ្នកជំនាញព្រំដែនខ្មែរ និងសម្តេចឪ នរោត្តម សីហនុ ព្រមទាំងសកម្មជនព្រំដែនផង។ ***សន្ធិសញ្ញាទាំងឡាយណា ដែលយកមូលដ្ឋានសន្ធិញ្ញា ១៩៨៥ គឺបានន័យថា «មិនស្របច្បាប់ទេ»។ វាផ្ទុយពីមាត្រា២ និងមាត្រា៥៥ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ហើយផ្ទុយនឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ១៩៩១ ចំណុច ២.ឃ។***

- កំណត់ហេតុប្រជុំគណៈកម្មាធិការព្រំដែនខ្មែរ (លោក វ៉ា គឹមហុង ប្រធាន) និងវៀតណាម (លោក វូ យុង) ថ្ងៃទី ០៤-០៧ មេសា ២០០៧ គឺថា«***សុំអ្នកបច្ចេកទេសវៀតណាម, បោះបង្គោលព្រំដែនតាម ផែនទីយូធីអឹម ខ្នាត 1/50.000*** *(ផែនទីអាមេរិកាំង ផ្គុយពីមាត្រា២ រដ្ឋធម្មនុញ្ញ)* ***និងប្រើ ផែនទីបោន 1/100.000*** *(បោះពុម្ពឡើងវិញនៅវៀតណាម បើតាមលោក វ៉ា គឹមហុង ថ្លែងថ្ងៃទី ០២ កក្កដា ២០១៥)។* ***ហើយឯកសារនានា រឿងព្រំដែន ត្រូវរក្សាជាការសម្ងាត់***»។

**ប្រវត្តិបោះបង្គោលព្រំដែនគោក** (៣ ដំណាក់កាល)

- តាមអនុសញ្ញាបារាំង កម្ពុជា និង កូសាំងស៊ីន ឆ្នាំ១៨៧៣ (សម័យអាណានិគមបារាំង) **បោះបង្គោលព្រំដែន ១២៤ បង្គោល** ជាមួយវៀតណាម។ វាគឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ ដែលទទួលស្គាល់ដោយសន្និសីទ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឆ្នាំ ១៩៥៤ ក្នុងនោះក៏មានវៀតណាម ឡាវ ចូលរួមទទួលស្គាល់ដែរ។ ហើយរឿងនេះ ត្រូវបានរំលឹកឡើងវិញជាថ្មី នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១។
- តាមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ជាមួយវៀតណាម ១៩៨៥ ជាសន្ធិសញ្ញាខុសច្បាប់ ដែលភាគីទាំងពីរ បានបោះបង្គោលព្រំដែន **៧២ បង្គោល។** ក្រុមអ្នកជំនាញព្រំដែន និង សម្តេចតា នរោត្តម សីហនុ ថា«**វៀតណាម បោះបង្គោលព្រំដែន រំកិលចូលក្នុងទឹកដីខ្មែរ**»។

- តាមសន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ ២០០៥ រវាងកម្ពុជា និងវៀតណាម **ត្រូវបោះបង្គោល ៣៧៥ បង្គោល** ជាបង្គោលថ្មី ដ៏ចម្រូងចម្រាស ដែលរងការចោទប្រកាន់បន្ថែមថា «**ធ្វើឲ្យបាត់បង់បូរណភាពទឹកដីបន្ថែម ទៅវៀតណាម**»។ ប្រទេសទាំងពីរ បោះបង្គោលបាន ៨៤% (បោះបាន ៣១៥ បង្គោល) មកដល់ដំណាច់ឆ្នាំ ២០១៩។ រួមជាមួយគ្នានេះ ប្រទេសទាំងពីរ ធ្វើសន្ធិសញ្ញាបំពេញបន្ថែមថ្មី ហៅថា សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ ២០១៩ គឺបន្ថែមខ្លឹមសារទៅលើ សន្ធិសញ្ញាព្រំដែន ១៩៨៥ និង ២០០៥។

**ជុំវិញរឿង កោះត្រល់**

- កោះត្រល់ និងប្រជុំកោះខ្មែរ នៅតែត្រូវបានសរសេរក្នុងសៀវសិក្សា «**ភូមិវិទ្យា**» **ថ្នាក់ទី៧ ឆ្នាំ១៩៨៥** នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា របស់លោក ហ៊ុន សែន ជាសម័យវៀតណាម ត្រួតត្រាកម្ពុជា។
- លោក ស៊ាន ប៉េងសែ អ្នកជំនាញផែនទីព្រំដែនខ្មែរ ថ្ងៃទី ២២ កុម្ភៈ ២០១៦ បញ្ជាក់ថា *បើតាមខ្សែបន្ទាត់ប្រេវីយេ (Brévié)* ***គឺកោះត្រល់ (មានផ្ទៃ ៥៧៤ គ.ម.ក្រឡា) ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសកម្ពុជា ពីព្រោះវា មានផ្ទៃដីខ្ពង់រាបាតសមុទ្រ ជាប់នឹងឆ្នេរសមុទ្រខ្មែរ ខេត្តកំពត។*** *វាមានចម្ងាយ ១៥ គីឡូម៉ែត្រ ពីខេត្តកំពត ហើយមានចម្ងាយ ៤៥ គីឡូម៉ែត្រ ពីតំបន់ហាទៀង ប្រទេសវៀតណាម (កម្ពុជាក្រោម)។*

- សម្តេចតា រោត្តម សីហនុ ផ្ញើព្រះរាជសារពីទីក្រុងប៉េកាំង ថ្ងៃទី ១៦ តុលា ២០០៤ ថា «ចំពោះខ្ញុំ ក្រោយពីបារាំងសែសថ្វាយរាជសម្បត្តិឲ្យខ្ញុំ ខ្ញុំបានរារាំងប្រទេសថៃ ប្រទេសវៀមណាម ដែលខ្លាំងជាងយើង កុំឲ្យមកលេបត្របាក់ពង្រួញទំហំទឹកដីខ្មែរយើងតទៅទៀតបាន»។ «កើតមកជាខ្មែរ គ្មានអ្នកណាម្នាក់ ដែលមិនស្រលាញ់ជាតិ ស្រលាញ់កម្ពុជាក្រោម និងកោះត្រល់ នោះទេ»។ «**ដូច្នេះ ខ្ញុំសូមជនរួមជាតិ មេត្តាបែងចែកឲ្យច្បាស់លាស់ពីៈ នរោត្តម សីហនុ មិនដែលទទួលស្គាល់ថា ស្របច្បាប់ និងសមហេតុផលអំពី កម្ពុជាក្រោម កោះត្រល់ បានទៅបារាំង ឬ វៀតណាម** នោះទេ»។

- លោក ប្រេវីយេ (Brévié, ឬឈ្មោះពេញ Jules Brévié) ជាអាណាព្យាបាលរបស់បារាំង ប្រចាំនៅឥណ្ឌូចិន ថ្ងៃទី ៣១ មករា ១៩៣៩ ត្រូវបានបកប្រែក្រៅផ្លូវការថា កោះត្រល់ ត្រូវបានដាក់ឲ្យខាងកូសាំងស៊ីន «**គ្រប់គ្រប់គ្រងខាងផ្នែករដ្ឋបាល និងប៉ូលីស**»ប៉ុណ្ណោះ ប៉ុន្តែកោះនេះ នៅតែជាកម្មសិទ្ធិរបស់ខ្មែរ។ លោក ប្រេវីយេ បញ្ជាក់យ៉ាងច្បាស់ថា *«ខ្ញុំសូមជម្រាបលោក* {ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មហាក្សត្រខ្មែរ} *ថា ខ្ញុំទើបនឹងបានពិនិត្យមើលសារជាថ្មី ម្តងទៀត នៅលើចំណោមរឿងចង្កោមកោះ ដែលនៅក្នុងឈូងសមុទ្រ សៀម ដែលមានការទាស់ទែងគ្នា រវាងប្រទេសកម្ពុជា និង កូសាំងស៊ីន។ ស្ថានភាពនៃ* ***ចង្កោមកោះនេះ ដែលមានរាយ នៅតាមបណ្តោយ ឆ្នេរសមុទ្រខ្មែរ ហើយដែលមានខ្លះ ស្ថិតនៅសែនជិតឆ្នេរសមុទ្រ របស់ខ្មែរ ដែលដី(ល្បាប់) ដែលកំពុងដុះ និងចេះតែបន្តដុះនេះ នឹងភ្ជាប់កោះទាំងនេះ ទៅនឹងឆ្នេរសមុទ្រ របស់ប្រទេសកម្ពុជា ក្នុង រយៈពេលដ៏ខ្លីខាងមុខ។ តាមការសមហេតុសមផល និង តាមរបៀបភោគម្ភសាស្ត្រ ជាការចាំបាច់ ត្រូវតែដាក់កោះទាំងនេះ ឲ្យនៅក្រោមការត្រួតត្រា នៃរាជការរបស់ប្រទេសកម្ពុជា***»។

- លោក ប្រេវីយេ បញ្ជាក់ក្នុងលិខិតថា កោះទាំងឡាយ ដែលស្ថិតនៅខាងត្បូង ខ្សែបន្ទាត់នេះ សរុបទាំង កោះហ្វូកុក (កោះត្រល់) ទាំងមូល ត្រូវនៅក្រោមការគ្រប់គ្រងរបស់ កូសាំងស៊ីន តទៅទៀត។ ត្រូវដឹងថា *ខ្សែបន្ទាត់ខណ្ឌសីមា* ***ដែលបានកំណត់នេះ ព័ទ្ធកោះហ្វូកុក តាមភាគខាងជើង ដោយនៅចម្ងាយ ៣ គីឡូម៉ែត្រ*** ពីចំណុចនានា ដែលនៅខាងជើងបំផុត នៃកោះនេះ។ ក៏ប៉ុន្តែ *នេះគ្រាន់តែជាការគ្រប់គ្រងផ្នែករដ្ឋបាល និងប៉ូលីសប៉ុណ្ណោះ* ចំណែកបញ្ហាអនិស្សរភាព (ក្រោមចំណុះ) (De pendanco) **នៃដែនដី នៃកោះទាំងនេះ នៅទុកដោយឡែកដដែល។**

- មានមតិមួយយល់ច្រឡំថា កោះត្រល់ ត្រូវបានវៀតណាម កាន់កាប់តាំងពីថ្ងៃទី ២៧ កញ្ញា ១៩៤៩ បន្ទាប់ពីអាណានិគមបារាំង **ផ្ទេរ ប្រគល់**ទឹកដីកម្ពុជាក្រោម (ឬ កូសាំងស៊ីន) ទៅឲ្យវៀតណាម។ ហើយរដ្ឋាភិបាលលោក ហ៊ុន សែន ក៏ខំនិយាយតាមគេ ជាពិសេសគឺនិយាយតាមវៀតណាម ដើម្បីតម្រូវចិត្តរបស់វៀតណាម។

- លោក ស៊ាន ប៉េងសែ ថ្ងៃទី២២ កុម្ភៈ ២០១៦ បានស្តីបន្ទោសលោក ហ៊ុន សែន ថា«**មិនចេះស្រឡាញ់ជាតិ**» បានកាត់កងខ្សែបន្ទាត់ព្រំដែន និងដែនសមុទ្រមួយភាគ ទៅឲ្យវៀតណាម។ *លោក ប៉េងសែ បញ្ជាក់ថា កោះត្រល់ ត្រូវបានវៀតណាម ចាប់ផ្តើមកាន់កាប់ បន្ទាប់ពីមានសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងដែនទឹកប្រវត្តិសាស្ត្រ ឆ្នាំ១៩៨២ (ថ្ងៃទី ៧ ខែកក្កដា ១៩៨២)* ធ្វើឡើងក្នុងសម័យ វៀតណាម ត្រួតត្រាកម្ពុជា។ កាលនោះលោក ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានលើកបន្តុបដោយវៀតណាម។

- សន្ធិសញ្ញាដែនទឹក ១៩៨២ និង សន្ធិសញ្ញាព្រំដែនគោក ១៩៨៥ ត្រូវបានរដ្ឋាភិបាលលោក ហ៊ុន សែន បន្តអនុវត្តដដែល ហើយនៅឆ្នាំ ២០០៥ លោក ហ៊ុន សែន និងវៀតណាម បានផ្តល់សច្ចាប័នរួមគ្នា លើសន្ធិសញ្ញាព្រំដែនបំពេញបន្ថែមថ្មី (សន្ធិសញ្ញាព្រំដែនគោក) បើទោះជាវាខុសច្បាប់ក៏ដោយ។ សន្ធិសញ្ញាព្រំដែនទាំងនេះ វាផ្ទុយនឹងមាត្រា១ ចំណុច ២.ឃ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១, វាផ្ទុយពីមាត្រា២ និងមាត្រា៥៥ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

..................